# សមាគមសម្ភព និងរោគស្ត្រីវិទ្យាកម្ពុជា

## CAMBODIAN SOCIETY OF GYNECOLOGY & OBSTETRICS (S.C.G.O.)

ព្រឹត្តិបត្រព័ត៌មាន

លេខ១ ត្រីមាសទី១ (ខែតុលា-ធ្នូ ២០១៥)



## មាតិកា

១-មតិស្វាគមន៍របស់ប្រធានសមាគមសម្ភព និងរោគស្ត្រីវិទ្យាកម្ពុជា

២-ប្រវត្តិសង្ខេបរបស់សមាគមសម្ភព និងរោគស្ត្រីវិទ្យាកម្ពុជា

៣- <គោលដៅ> គម្រោងសំរាប់សុខភាពស្ត្រី និងជម្ងឺមហារីកមាត់ស្បូន

៤-រចនាសម្ព័ន្ធគ្រប់គ្រង

៥-សកម្មភាពរបស់សមាគមសម្ភព និងរោគស្ត្រីវិទ្យាកម្ពុជានៅប្រទេសជប៉ុន

៦-ហេតុអ្វីបានជាការចូលជាសមាជិកសមាគមសម្ភព និងរោគស្ត្រីវិទ្យាកម្ពុជាមានសារៈសំខាន់?

៧-ទិវាលើកទី១៤នៃសមាគម(ការរកឃើញនិងព្យាបាលជម្ងឺមហារីកមាត់ស្បូនទាន់ពេលគឺសង្គ្រោះជីវិត)

៨-ស្នើសុំអោយក្រុមការងារអនុវត្តគម្រោងធ្វើការរៀបចំពិធីសារស្តង់ដារ និងការចុះឈ្មោះជាស្តង់ដារ




# មតិស្វាគមន៍របស់ប្រធានសមាគមសម្ភព និងរោគស្ត្រីវិទ្យាកម្ពុជា



ខ្ញុំបាទសាស្ត្រាចារ្យ គុំ កាណាល់ ប្រធានសមាគមសម្ភព និងរោគស្ត្រីវិទ្យាកម្ពុជា (សសសក) តំណាងអោយគណៈកម្មាធិការប្រតិបត្តិកណ្តាលទាំងអស់របស់សមាគមសម្ភព និងរោគស្ត្រីវិទ្យាកម្ពុជា សូមជម្រាបសួរ ប្រិយមិត្ត និងសមាជិក សមាជិការបស់សមាគមទាំងអស់ជាទីគោរពរាប់អាន។

សមាគមរបស់យើងបានចាប់កំណើតឡើងកាលពីឆ្នាំ១៩៩៧ ដោយសារតម្រូវការជំនាញរបស់មហាវិទ្យាល័យវេជ្ជសាស្ត្រ និងមានការគាំទ្រពីក្រសួងសុខាភិបាលហើយមានសមាជិកភាពជាមន្ត្រីរាជការជំនាញសម្ភព និងរោគស្ត្រីដែលកំពុងធ្វើការនៅតាមមន្ទីរសម្ភពនៅក្នុងទីក្រុងភ្នំពេញ។សមាគមបានចងក្រងបាននូវលក្ខន្តិកៈ និងក្រុមប្រិក្សាភិបាលដើម្បីដឹកនាំសមាគម។ កាលនោះចំនួនសមាជិកមានត្រឹមតែ២៥រូបប៉ុណ្ណោះ។

គោលដៅរបស់សមាគមគឺដើម្បីលើកកំពស់មនសិការជាតិ និងអន្តរជាតិព្រមទាំងបង្កើនស្មារតីទទួលខុសត្រូវលើកិច្ចសហប្រតិបត្តិការនិងការជឿនលឿននៃវិទ្យាសាស្ត្រតាមការចូលរួមចំណែកបំពេញតួនាទីនិងមុខដំណែងក្នុងសង្គមជាតិ និងអន្តរជាតិជំរុញអោយមានសន្ទុះកាន់តែខ្លាំងរាល់សកម្មភាពបណ្តុះបណ្តាលនិងស្រាវជ្រាវវិទ្យាសាស្ត្រតាមរយៈការចុះជួយពង្រឹងចំណេះដឹង និងចំណេះធ្វើនៅនឹងកន្លែងធ្វើការងារក៏ដូចជាការជួបជុំគ្នាផ្នែកគរុកោសល្យនិងវិទ្យាសាស្ត្រ។

ខ្ញុំមានក្តីសោមនស្សរីករាយ និងជម្រាបជូនដំណឹងថា សមាគមមានបំណងផ្តល់នូវចំណេះដឹងនិងព័ត៌មានតាមរយៈព្រឹត្តិបត្រចេញផ្សាយបន្តបន្ទាប់ដែលផ្តល់ព័ត៌មានផ្អែកលើភស្តុតាង សម្រាប់យកទៅអនុវត្តក្នុងការងារជាក់ស្តែងរបស់ខ្លួនក្នុងការផ្តល់សេវា។

ជាចុងបញ្ចប់  ខ្ញុំសូមជូនពរដល់គណៈកម្មាធិការនិងសមាជិកសមាគមសម្ភពនិងរោគស្ត្រីវិទ្យាកម្ពុជាទាំងអស់ ជួបប្រទះតែសេចក្តីសុខ និងសម្រេចបានជោគជ័យគ្រប់ភារកិច្ច។

សូមប្រសិទ្ធិពរនិងគោរពជូននូវពុទ្ធពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។



# ប្រវត្តិសង្ខេបរបស់សមាគមសម្ភព និងរោគស្ត្រីវិទ្យាកម្ពុជា

សមាគមសម្ភព និងរោគស្ត្រីវិទ្យាកម្ពុជាត្រូវបានបង្កើតឡើងតាំងពីឆ្នាំ១៩៩៧ ប៉ុន្តែយើងរៀបចំឡើងវិញនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៥ នៅរាជធានីភ្នំពេញដោយលោកសាស្ត្រាចារ្យវេជ្ជបណ្ឌិត គុំ កាណាល់ ដែលត្រូវបានគណៈកម្មាធិការសមាគម សម្រេចតែងតាំងជាប្រធានសមាគមសម្ភពនិងរោគស្ត្រីវិទ្យាកម្ពុជា។

ដោយយោងតាមស្ថានភាពនៅក្នុងប្រទេសកម្ពុជា គេប៉ាន់ប្រមាណថាជារៀងរាល់ឆ្នាំស្ត្រីប្រមាណ ១៥០០នាក់ត្រូវបានគេរកឃើញថាមានជំងឺមហារីកមាត់ស្បូនថ្មី ហើយយ៉ាងហោចណាស់ស្ត្រី៩០០នាក់ស្លាប់ដោយសារជំងឺនេះ។បន្ទុកនៃជំងឺមហារីកមាត់ស្បូននៅក្នុងប្រទេសកម្ពុជា មានទិន្នន័យឈានមុខគេក្នុងចំណោមមហារីកទាំងអស់។នេះគឺជាបន្ទុកធ្ងន់ធ្ងរចំពោះស្ត្រី ហើយក៏ជាបញ្ហាសុខភាពសាធារណៈសំខាន់បំផុតរបស់ក្រសួងសុខាភិបាលកម្ពុជាផងដែរ។

ជាមូលហេតុចំបងនេះហើយជាការចាំបាច់ណាស់ដែលកម្ពុជាត្រូវមានយុទ្ធសាស្ត្រជាតិមួយដែលមានប្រសិទ្ធភាពបំផុតសំរាប់បរិបទកម្ពុជា។នាយកដ្ឋានការពារសុខភាពនៃក្រសួងសុខាភិបាលបានលើកគម្រោងសាកល្បងចំនួនបីនឹងត្រូវចាប់ផ្តើមដោយមានយុទ្ធសាស្ត្រអនុវត្តន៍ផ្សេងៗគ្នាក្រោមការឧបត្ថម្ភគាំទ្រថវិកាពីធនាគារពិភពលោកក្នុងស្រុកប្រតិបត្តិព្រៃឈរ កងមាសនៃខេត្តកំពង់ចាម។

ដោយឡែកសមាគមសម្ភព និងរោគស្ត្រីវិទ្យាកម្ពុជាសហការជាមួយសមាគមសម្ភពរោគស្ត្រីជប៉ុន ដោយមានការគាំទ្រពីអង្គការ JICA បានរៀបចំគម្រោងពិនិត្យស្រាវជ្រាវរកជំងឺនិងព្យាបាលមហារីកមាត់ស្បូន នៅដំណាក់កាលដំបូងសម្រាប់ស្ត្រីដែលជាកម្មការិនីរោងចក្រនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសទីក្រុងភ្នំពេញ និងស្ត្រីទាំងអស់ដែលចូលមកប្រើប្រាស់សេវាក្នុងមន្ទីរពេទ្យបីក្នុងរាជធានីភ្នំពេញរួមមានមន្ទីរពេទ្យនៃ មជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក មន្ទីរពេទ្យកាល់ម៉ែត្រ និងមន្ទីរពេទ្យមិត្តភាពកម្ពុជាសូវៀតដើម្បីចូលរួមកាត់បន្ថយអត្រាមរណភាព និងចូលរួមពង្រឹងប្រព័ន្ធពិនិត្យស្រាវជ្រាវតាមដានព្យាបាលនៃជម្ងឺមហារីកមាត់ស្បូននេះ។សមាគមទាំងពីរសមាគមសម្ភព និងរោគស្ត្រីវិទ្យាកម្ពុជានិងសមាគមសម្ភពរោគស្ត្រីជប៉ុន សង្ឃឹមជឿជាក់ថា លទ្ធផលនៃគម្រោងនេះ ជាសមិទ្ធិផលមួយដែលអាចរួមចំណែកក្នុងការកាត់បន្ថយអត្រាមរណភាពរបស់ស្ត្រីនិងកាត់បន្ថយអាំងស៊ីដង់នៃជំងឺមហារីកមាត់ស្បូន ហើយអនុសាសន៍នេះអាចយកមកប្រើប្រាស់ទូទាំងប្រទេសបាន។




# <គោលដៅ> គម្រោងសំរាប់ សុខភាពស្ត្រីនិងជម្ងឺមហារីកមាត់ស្បូន



-ដើម្បីបង្កើតឲ្យមានការយល់ដឹងអំពីជំងឺមហារីកមាត់ស្បូននិងឥទ្ធិពលរបស់វាដល់ស្ត្រីពិសេសជាកម្មការនីរោងចក្រដល់អ្នកគ្រប់គ្រងរោងចក្រចំណុច

-ចំនួនស្ត្រីពិសេស មានអាយុក្នុងចន្លោះ៣០-៤៩ឆ្នាំជាកម្មការនីរោងចក្រមកពិនិត្យស្រាវជ្រាវនិងព្យាបាល ដើម្បីបង្ការជំងឺមហារីកមាត់ស្បូនមានចំនួនកើនឡើង

-ដើម្បីវាយតម្លៃប្រសិទ្ធភាពនៃការបង្ការជំងឺមហារីកមាត់ស្បូនក្នុងមន្ទីរពេទ្យនៃមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក មន្ទីរពេទ្យកាល់ម៉ែត្រ និងមន្ទីរពេទ្យមិត្តភាពកម្ពុជាសូវៀត។

-ដើម្បីពង្រឹងប្រព័ន្ធពិនិត្យស្រាវជ្រាវតាមដានព្យាបាលនៃជម្ងឺមហារីកមាត់ស្បូននេះក្នុងមន្ទីរពេទ្យនៃមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក មន្ទីរពេទ្យកាល់ម៉ែត្រ និងមន្ទីរពេទ្យមិត្តភាពកម្ពុជាសូវៀតនិងនៅក្នុងប្រទេសកម្ពុជានាពេលអនាគត។



Photo source: UNFPA



Photo credit: PPSEZ blog



# រចនាសម្ព័ន្ធ

# សមាគមសម្ភព និងរោគស្ត្រីវិទ្យាកម្ពុជា(សសសក)

## Société Cambodgienne de Gynécologie et d´obstétrique ( SCGO )

## Cambodian Society of Gynecology and Obstetrics

**សន្និបាត**

**ក្រុមប្រឹក្សាភិបាល**

ប្រធាន

សាស្ត្រាចារ្យ គុំ កាណាល់

**អនុប្រធាន**

សាស្ត្រាចារ្យ គ្រុយ លាងស៊ីម

សាស្ត្រាចារ្យ ទុង រដ្ឋាវី

**អគ្គលេខាធិការ**

សាស្ត្រាចារ្យ សៀង ថារិទ្ធ

**គណៈកម្មការវិទ្យាសាស្ត្រ**

ប្រធាន

សាស្ត្រាចារ្យ សាន់ ច័ន្ទសឿន

**គណៈកម្មការទំនាក់ទំនង**

ប្រធាន

សាស្ត្រាចារ្យជំនួយ ប៉ិច សុធី

**ហិរញ្ញិក**

សាស្ត្រាចារ្យជំនួយ គាំ ផល្លី



# សកម្មភាពរបស់សមាគមនៅប្រទេសជប៉ុន



គម្រោងសហការរបស់ SCGO-JSOG បានចុះហត្ថលេខាលើអនុស្សរណៈនៅក្រសួងសុខាភិបាល ប្រទេសកម្ពុជា នៅថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ ២០១៥ ក្នុងគម្រោងពង្រឹងការថែទាំសុខភាពស្ត្រីដែលជាកម្មការនីដោយផ្តោតទៅលើជំងឺមហារីកមាត់ស្បូន។

ក្រុមប្រឹក្សាភិបាល៤នាក់និងក្រុមការងារអនុវត្តរបស់សមាគមសម្ភព និងរោគស្ត្រីវិទ្យាកម្ពុជាបានចូលរួមកិច្ចប្រជុំ និងវគ្គបណ្តុះបណ្តាលនៅការិយាល័យ JSOG នៅកណ្តាលទីក្រុងតូក្យូ ប្រទេសជប៉ុននាខែកញ្ញា ឆ្នាំ២០១៥ ដោយពួកគាត់បានទទួលចំណេះដឹងច្រើនពីគំនិតមូលដ្ឋានដើម្បីប្រតិបត្តិការគ្លីនិកក្នុងការគ្រប់គ្រងជម្ងឺមហារីកមាត់ស្បូន។













## ហេតុអ្វីបានជាការចូលជាសមាជិកសមាគមសម្ភព និង រោគស្ត្រីវិទ្យាកម្ពុជាមានសារៈសំខាន់?








- សមាគមសម្ភព និងរោគស្ត្រីវិទ្យាកម្ពុជា អាចលើកកំពស់តួនាទីវិជ្ជាជីវៈ ក្នុងក្រសែភ្នែករបស់ប្រជាពលរដ្ឋ ដោយមានការគាំទ្រពីសំណាក់រាជរដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយនានា។
- សមាគមសម្ភព និងរោគស្ត្រីវិទ្យាកម្ពុជា អាចធ្វើអោយវិជ្ជាជីវៈសម្ភព និងរោគស្ត្រីមានការរីកចំរើនតាមរយៈកិច្ច សហប្រតិបត្តិការជាមួយរាជរដ្ឋាភិបាល ក្រុមប្រឹក្សាគណៈគ្រូពេទ្យកម្ពុជា និង អង្គការក្រៅរដ្ឋាភិបាលនានា។
- សមាគមសម្ភពនិងរោគស្ត្រីវិទ្យាកម្ពុជា អាចផ្តល់ការគាំទ្រដល់ការអប់រំនិងកាលានុវត្តភាពក្នុងការអភិវឌ្ឍន៍វិជ្ជាជីវៈតាមរយៈការចុះអភិបាលនិងសិក្ខាសាលា។
- សមាគមសម្ភព និងរោគស្ត្រីវិទ្យាកម្ពុជា អាចតំណាងឲ្យអ្នកផ្តល់សេវាធ្មបកម្ពុជា ថ្នាក់ក្រោមជាតិ ថ្នាក់ជាតិ និងអន្តរជាតិ
- សមាគមសម្ភព និងរោគស្ត្រីវិទ្យាកម្ពុជា អាចផ្តល់វេទិកាមួយដែលគ្រូពេទ្យអាចគាំទ្រគ្នាទៅវិញទៅមកតាមរយៈការចែករំលែក ចំណេះដឹង ជំនាញនិងបទពិសោធន៍។
- តួនាទីដ៏សំខាន់បំផុតរបស់សមាជិកសមាគម គឺខិតខំធ្វើយ៉ាងណាដើម្បីផ្តល់សេវាឲ្យល្អបំផុត ដល់ស្ត្រីទារក ព្រមទាំងក្រុមគ្រួសារនិងសហគមន៍របស់ពួកគេ។

ការចូលជាសមាជិកសមាគមសម្ភព និងរោគស្ត្រីវិទ្យាកម្ពុជា គឺជួយខ្លួនឯងនិងចូលរួមចំណែកក្នុងសង្គម។



## ទិវាលើកទី១៨នៃសមាគមសម្ភព និងរោគស្ត្រីវិទ្យាកម្ពុជា
## (ការរកឃើញនិងព្យាបាលជម្ងឺមហារីកមាត់ស្បូនទាន់ពេលគឺសង្គ្រោះជីវិត)

សមាគមសម្ភព និងរោគស្ត្រីវិទ្យាកម្ពុជាបានរៀបចំទិវាលើកទី១៩ស្តីពីការរកឃើញនិងព្យាបាលជម្ងឺមហារីកមាត់ស្បូនទាន់ពេលគឺសង្គ្រោះជីវិតដែលប្រព្រឹត្តទៅនៅថ្ងៃទី២០-២១ ខែវិច្ឆិកា ឆ្នាំ២០១៥ នៅសណ្ឋាគារ ភ្នំពេញ រាជធានីភ្នំពេញ។ ក្នុងឱកាសនេះ លោកសាស្ត្រាចារ្យវេជ្ជ គុំ កាណាល់បានអញ្ជើញ វាគ្មិនមកពីប្រទេសជប៉ុន ប្រទេសឥណ្ឌា និង អ្នកចូលរួមមកពីបណ្តាមន្ទីរពេទ្យ ខេត្ត-ក្រុងនានាបកស្រាយនិងចែករំលែកគ្នាទៅវិញទៅមក។





## ស្នើសុំអោយក្រុមការងារអនុវត្តគម្រោងធ្វើការរៀបចំ
## ពិធីសារស្តង់ដារ និងការចុះឈ្មោះជាស្តង់ដារ

សមាគមសម្ភព និងរោគស្ត្រីវិទ្យាកម្ពុជាបានស្នើសុំឲ្យក្រុមការងារអនុវត្តទាំង៦នាក់ដែលមកពីមន្ទីរពេទ្យកាល់ម៉ែត មន្ទីរពេទ្យមិត្តភាពកម្ពុជាសូវៀត និងមន្ទីរពេទ្យនៃមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក(មន្ទីរពេទ្យជប៉ុន) ធ្វើការរៀបចំពិធីសារស្តង់ដារ (protocol) និងការចុះឈ្មោះជាស្តង់ដារសម្រាប់ ការបង្ការ និងការគ្រប់គ្រងជាមុននូវជម្ងឺមហារីកមាត់ស្បូន។ការរៀបចំធ្វើ protocol គឺត្រូវបានធ្វើឡើងរៀងរាល់ថ្ងៃពុធ ពេលវេលារសៀល។

